(២៨២) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អា-ស្រ័យខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... វត្ថុ អាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយ អាស្រ័យវត្ថុ មហាភូត ៣ អាស្រ័យមហាភូត ១ មហាភូត ២ អាស្រ័យមហាភូត ២ ចិត្ត-សមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

(២៨៣) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំង-ឡាយ ដែលដល់នូវការសន្សំផង មហាភូតទាំងឡាយផង ។

អបចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមិ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អបចយគាមី ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(២៥៤) អាចយគាមី ធម្មំ បដិច្ច អាចយគាមី ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អាចយគាមី ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(២៥៥) អបចយគាមី ធម្មំ បដិច្ច អបចយគាមី ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អបចយគាមី ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(២៥៦) នេវាចយគាមិនាបចយគាមី ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមិ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា នេវាចយគាមិនាបចយគាមី ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ... បដិសន្ធិក្ខណេ វត្ថុំ បដិច្ច ខន្ធា ។

(២៥៧) អាចយគាមី ធម្មំ បដិច្ច អាចយគាមី ធម្មោ ឧប្បជ្ជតិ អធិបតិប្បច្ចយា តីណិ ។ ... អបចយគាមិ ធម្មោ ... អធិបតិប្បច្ចយា តីណិ ។

ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការមិនសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំផង មហាភូតទាំងឡាយផង ។

(២៥៤) ធម៌ ដែលដល់នូវការសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវការសន្សំ នូវខន្ធ ២ ... ។

(២៥៥) ធម៌ ដែលដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការមិនសន្សំ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវការមិនសន្សំ នូវខន្ធ ២ ... ។

(២៥៦) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យខន្ធ ២ ... ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

(២៥៧) ធម៌ ដែលដល់នូវការសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ (បានដល់ពាក្យបុច្ឆា និងវិសជ្ជនា) ៣ លើក ។ ... ធម៌ ដែលដល់នូវការមិនសន្សំ ... ព្រោះអធិបតិប្បច្ច័យ (បានដល់ពាក្យបុច្ឆា និងវិសជ្ជនា) ៣ លើក ។

នេវាចយគាមិនាបចយគាមឹ ធម្មំ បដិច្ច នេវាចយគា-
មិនាបចយគាមី ធម្មោ ... ឯកំ ។ បដិសន្ធិ ខន្ធេ ។
ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា ។ បេ ។
មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ឧបាទារូបំ ។
អាចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ
បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ឧប្បជ្ជតិ
អធិបតិប្បច្ចយា អាចយគាមី ខន្ធេ ច មហាភូតេ ច
បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ អបចយគាមិញ្ច នេវាចយ-
គាមិនាបចយគាមិញ្ច ធម្មំ បដិច្ច នេវាចយគាមិនា-
បចយគាមី ធម្មោ ... អធិបតិប្បច្ចយា អបចយគាមី
ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(២៤៨) អាចយគាមឹ ធម្មំ បដិច្ច អាចយគាមី
ធម្មោ ... អនន្តរប្បច្ចយា សមនន្តរប្បច្ចយា សហ-
ជាតប្បច្ចយា សព្វេបិ មហាភូតា នាគតា ។ អញ្ញ-
មញ្ញប្បច្ចយា ចិត្តសមុដ្ឋានម្បិ កដត្តារូបម្បិ ឧបា-
ទារូបម្បិ នត្ថិ ។ និស្សយប្បច្ចយា ឧបនិស្សយប្បច្ច-
យា បុរេជាតប្បច្ចយា អាសេវនប្បច្ចយា កម្មប្បច្ច-
យា វិបាកប្បច្ចយា អាហារប្បច្ចយា ឥន្ទ្រិយប្បច្ចយា

ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌
ដែលមិនដល់នូវការសន្សំ ... មិនដល់នូវការមិនសន្សំ បានដល់
ការៈ១ ។ បដិសន្ធិ មិនមានទេ ។ មហាភូត ៣ អាស្រ័យមហា-
ភូត ១ ។ បេ ។ ចិត្តសមុដ្ឋានរូប និងឧបាទារូប អាស្រ័យមហាភូត
ទាំងឡាយ ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិន
សន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់
នូវការសន្សំ មិនដល់នូវការមិនសន្សំផង កើតឡើង ព្រោះអធិប-
តិប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវ
ការសន្សំផង មហាភូតទាំងឡាយផង ។ ធម៌ ដែលមិនដល់នូវការ
សន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការមិនសន្សំ
ផង មិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះអធិ-
បតិប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវ
ការមិនសន្សំផង មហាភូតទាំងឡាយផង ។

(២៤៨) ធម៌ ដែលដល់នូវការសន្សំ អាស្រ័យធម៌ ដែលដល់នូវ
ការសន្សំ ... ព្រោះអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ និងសហជាត-
ប្បច្ច័យ ឯមហាភូតទាំងអស់ បណ្ឌិត គប្បីធ្វើចុះ ។ ចិត្តសមុដ្ឋាន-
រូបក្តី កដត្តារូបក្តី ឧបាទារូបក្តី មិនមាន ព្រោះអញ្ញមញ្ញប្បច្ច័យទេ ។
ព្រោះនិស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អាសេ-
វនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ

ឈានបច្ចយា មគ្គបច្ចយា សម្បយុត្តបច្ចយា វិប្ប-យុត្តបច្ចយា អត្ថិបច្ចយា នត្ថិបច្ចយា វិគតបច្ចយា អវិគតបច្ចយា ។

(២៥៩) ហេតុយា នវ អារម្មណេ តីណិ អធិ-បតិយា នវ អនន្តរេ តីណិ សមនន្តរេ តីណិ ស-ហជាតេ នវ អញ្ញមញ្ញេ តីណិ និស្សយេ នវ ឧប-និស្សយេ តីណិ បុរេជាតេ តីណិ អាសេវនេ តីណិ កម្មេ នវ វិបាកេ ឯកំ អាហារេ នវ ឥន្ទ្រិយេ នវ ឈានេ នវ មគ្គេ នវ សម្បយុត្តេ តីណិ វិប្ប-យុត្តេ នវ អត្ថិយា នវ នត្ថិយា តីណិ វិគតេ តីណិ អវិគតេ នវ ។ ឯវំ គណេតព្វំ ។

អនុលោមំ ។

(២៦០) អាចយគាមឹ ធម្មំ បដិច្ច អាចយគាមិ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។

ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិ-ប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

(២៥៩) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះ ។

ចប់ អនុលោម ។

(២៦០) ធម៌ ដែលដល់នូវការសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

(៦៦១) នេវាចយគាមិនាបចយគាមី ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ... នហេតុប្បច្ចយា អហេតុកំ នេវាចយគាមិនាបចយគាមី ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... អហេតុកប្បដិសន្ធិក្ខណេ ខន្ធេ បដិច្ច វត្ថុ វត្ថុំ បដិច្ច ខន្ធា ឯកំ មហាភូតំ ... ពាហិរំ ... អាហារសមុដ្ឋានំ ... ឧតុសមុដ្ឋានំ ... អសញ្ញសត្តានំ ឯកំ មហាភូតំ បដិច្ច ។

(៦៦២) អាចយគាមី ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ... នអារម្មណប្បច្ចយា អាចយគាមី ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ អបចយគាមី ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ... នអារម្មណប្បច្ចយា អបចយគាមី ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(៦៦៣) នេវាចយគាមិនាបចយគាមី ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ... នអារម្មណប្បច្ចយា នេវាចយគាមិនាបចយគាមី ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ ខន្ធេ បដិច្ច វត្ថុ

(៦៦១) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ជាអហេតុកៈ នូវខន្ធ ២ ... វត្ថុ អាស្រ័យខន្ធទាំងឡាយ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធទាំងឡាយ អាស្រ័យវត្ថុ មហាភូត ១ ... ពាហិរៈ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ ។

(៦៦២) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំ ... ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការមិនសន្សំ ... ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនដល់នូវការមិនសន្សំ ។

(៦៦៣) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ វត្ថុ អាស្រ័យខន្ធទាំងឡាយ

ឯកំ មហាភូតំ ... ពាហិរំ ... អាហារសមុដ្ឋានំ ... ឧតុសមុដ្ឋានំ ... អសញ្ញសត្តានំ ... ។

(៦៦៤) អាចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ... នអារម្មណប្បច្ចយា អាចយគាមី ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(៦៦៥) អបចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ... នអារម្មណប្បច្ចយា អបចយគាមី ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(៦៦៦) អាចយគាមឹ ធម្មំ បដិច្ច អាចយគាមី ធម្មោ ឧប្បជ្ជតិ នអធិបតិប្បច្ចយា តីណិ ។ អបចយគាមឹ ធម្មំ បដិច្ច អបចយគាមី ធម្មោ ឧប្បជ្ជតិ នអធិបតិប្បច្ចយា អបចយគាមី ខន្ធេ បដិច្ច អបចយគាមី អធិបតិ ។ នេវាចយគាមិនាបចយគាមឹ ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ...

ក្នុងខណៈនៃបដិសន្ធិ មហាភូត ១ ... ពាហិរ ... អាហារៈ-សមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញសត្វ ... ។

(៦៦៤) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការសន្សំផង មហាភូតទាំងឡាយផង ។

(៦៦៥) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការមិនសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំផង មហាភូតទាំងឡាយផង ។

(៦៦៦) ធម៌ ដែលដល់នូវការសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ (បានដល់ពាក្យបុច្ឆានិងវិសជ្ជនា) ៣ លើក ។ ធម៌ ដែលមិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការមិនសន្សំ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺ អធិបតិ ដែលដល់នូវការមិនសន្សំ អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំ ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ...

នអធិបតិប្បច្ចយា នេវាចយគាមិនាបចយគាមិំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានំ រូបំ ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ ខន្ធេ បដិច្ច វត្ថុ វត្ថុំ បដិច្ច ខន្ធា ឯកំ មហាភូតំ ... ពាហិរំ ... ។ សង្ខិត្តំ ។ អសញ្ញសត្តានំ ឯកំ មហាភូតំ ... ។

(២៦៧) អាចយគាមិញ្ច នេវាចយគាមិនាបចយ-គាមិញ្ច ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមិ ធម្មោ ... នអធិបតិប្បច្ចយា អាចយគាមី ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(២៦៨) អាចយគាមិំ ធម្មំ បដិច្ច នេវាចយគា-មិនាបចយគាមិ ធម្មោ ... នអនន្តរប្បច្ចយា នសម-នន្តរប្បច្ចយា នអញ្ញមញ្ញប្បច្ចយា នឧបនិស្សយប្បច្ច-យា នបុរេជាតប្បច្ចយា កុសលត្តិកសទិសា សត្ត បញ្ហា ។ នបច្ឆាជាតប្បច្ចយា ។

(២៦៩) អាចយគាមិំ ធម្មំ បដិច្ច អាចយគាមិ ធម្មោ ឧប្បជ្ជតិ នអាសេវនប្បច្ចយា តីណិ ។ អបចយ-គាមិំ ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមិ ធម្មោ

ព្រោះនអធិបតិប្បច្ច័យ គឺ ខន្ធ ៣ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ នូវខន្ធ ២ ... វត្ថុ អាស្រ័យខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយ អា-ស្រ័យ វត្ថុ មហាភូត ១ ... ពាហិរ ... ។ សេចក្តីបំប្រួញ ។ នូវមហាភូត ១ របស់ពួកអសញ្ញសត្វ ... ។

(២៦៧) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះនអធិបតិប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការសន្សំផង មហាភូតទាំងឡាយផង ។

(២៦៨) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំ ... ព្រោះនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ នឧបនិស្សយប្បច្ច័យ និងន-បុរេជាតប្បច្ច័យ ប្រស្នាទាំង ៧ (នេះ) ប្រាកដស្មើដោយកុសលត្តិកៈដែរ ។ ព្រោះនបច្ឆាជាតប្បច្ច័យ ។

(២៦៩) ធម៌ ដែលដល់នូវការសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ (បានដល់ពាក្យបុច្ឆា និងវិសជ្ជនា) ៣ លើក ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការមិនសន្សំ

ឧប្បជ្ជតិ នអាសេវនប្បច្ចយា អបចយគាមី ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ នេវាចយគាមិនាបចយគាមិំ ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ... នអាសេវនប្បច្ចយា ឯកា បញ្ហា ។ សព្វេ មហាភូតា កាតព្វា ។

(២៧០) អាចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ... នអាសេវនប្បច្ចយា អាចយគាមី ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ អាចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមី ធម្មោ ឧប្បជ្ជតិ នអាសេវនប្បច្ចយា អបចយគាមី ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(២៧១) អាចយគាមិំ ធម្មំ បដិច្ច អាចយគាមី ធម្មោ ឧប្បជ្ជតិ នកម្មប្បច្ចយា អាចយគាមី ខន្ធេ បដិច្ច អាចយគាមិនី ចេតនា ។ អបចយគាមិំ ធម្មំ បដិច្ច អបចយគាមី ធម្មោ ...

ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំ ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះនអាសេវនប្បច្ច័យ បានដល់បញ្ហា ១ ។ មហាភូតទាំងអស់ បណ្ឌិត គប្បីធ្វើ ។

(២៧០) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះនអាសេវនប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការសន្សំផង មហាភូតទាំងឡាយផង ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំផង មហាភូតទាំងឡាយផង ។

(២៧១) ធម៌ ដែលដល់នូវការសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ដែលដល់នូវការសន្សំ អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ។ ធម៌ ដែលដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការសន្សំ ...

នកម្មប្បច្ចយា អបចយគាមី ខន្ធេ បដិច្ច អបចយគាមិ ចេតនា ។ នេវាចយគាមិនាបចយគាមី ធម្មំ បដិច្ច នេវាចយគាមិនាបចយគាមិ ធម្មា ... នកម្មប្បច្ចយា នេវាចយគាមិនាបចយគាមី ខន្ធេ បដិច្ច នេវាចយគាមិនាបចយគាមិ ចេតនា ពាហិរំ ... អាហារសមុដ្ឋានំ ... ឧតុសមុដ្ឋានំ ឯកំ មហាភូតំ ... ។

(២៧២) អាចយគាមី ធម្មំ បដិច្ច អាចយគាមិ ធម្មា ឧប្បជ្ជន្តិ នវិបាកប្បច្ចយា បរិបុណ្ណំ បដិសន្ធិ នត្ថិ ។បេ។ នអាហារប្បច្ចយា នឥន្ទ្រិយប្បច្ចយា នឈានប្បច្ចយា នមគ្គប្បច្ចយា នសម្បយុត្តប្បច្ចយា នវិប្បយុត្តប្បច្ចយា តីណិ ។ នោនត្ថិប្បច្ចយា នោវិគតប្បច្ចយា ។

(២៧៣) នហេតុយា ទ្វេ នអារម្មណេ បញ្ច នអធិបតិយា ឆ នអនន្តរេ បញ្ច នសមនន្តរេ បញ្ច នអញ្ញមញ្ញេ បញ្ច នឧបនិស្សយេ បញ្ច

ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ដែលដល់ទៅការមិនសន្សំ អាស្រ័យខន្ធទាំងឡាយ ដែលដល់ទៅការមិនសន្សំ ។ ធម៌ ដែលមិនដល់ទៅការសន្សំ មិនដល់ទៅការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់ទៅការសន្សំ មិនដល់ទៅការមិនសន្សំ ... ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ដែលមិនដល់ទៅការសន្សំ មិនដល់ទៅការមិនសន្សំ អាស្រ័យខន្ធទាំងឡាយ ដែលមិនដល់ទៅការសន្សំ មិនដល់ទៅការមិនសន្សំ ពាហិរៈ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន មហាភូត ១ ... ។

(២៧២) ធម៌ ដែលដល់ទៅការសន្សំ អាស្រ័យធម៌ ដែលដល់ទៅការសន្សំ ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺ បដិសន្ធិ ដ៏បរិបូណ៌ មិនមានទេ ។បេ។ ព្រោះនអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ នសម្បយុត្តប្បច្ច័យ និងនវិប្បយុត្តប្បច្ច័យ (បានដល់ពាក្យបុច្ឆា និងវិសជ្ជនា) ៣ លើក ។ ព្រោះនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ ។

(២៧៣) ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៥

នបុរេជាតេ សត្ត នបច្ឆាជាតេ នវ នអាសេវនេ សត្ត នកម្មេ តីណិ នវិបាកេ នវ នអាហារេ ឯកំ នឥន្ទ្រិយេ ឯកំ នឈានេ ឯកំ នមគ្គេ ឯកំ នសម្បយុត្តេ បញ្ច នវិប្បយុត្តេ តីណិ នោនត្ថិយា បញ្ច នោវិគតេ បញ្ច ។ ឯវំ គណេតព្វំ ។

បច្ចនីយំ ។

[៤៧៦] ហេតុប្បច្ចយា នអារម្មណេ បញ្ច ... នអធិបតិយា ឆ នអនន្តរេ បញ្ច នសមនន្តរេ បញ្ច នអញ្ញមញ្ញេ បញ្ច នឧបនិស្សយេ បញ្ច នបុរេជាតេ សត្ត នបច្ឆាជាតេ នវ នអាសេវនេ សត្ត នកម្មេ តីណិ នវិបាកេ នវ នសម្បយុត្តេ បញ្ច នវិប្បយុត្តេ តីណិ នោនត្ថិយា បញ្ច នោវិគតេ បញ្ច ។ ឯវំ គណេតព្វំ ។

អនុលោមបច្ចនីយំ ។

ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិត គប្បីរាប់យ៉ាងនេះ ។

ចប់ បច្ចនីយៈ ។

[៤៧៦] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិត គប្បីរាប់យ៉ាងនេះ ។

ចប់ អនុលោមបច្ចនីយៈ ។

(៦៧៥) ហេតុបច្ចយា អារម្មណេ ទ្វេ ... អនន្តរេ ទ្វេ សមនន្តរេ ទ្វេ សហជាតេ ទ្វេ អញ្ញមញ្ញេ និស្សយេ បុរេជាតេ អាសេវនេ កម្មេ ទ្វេ វិបាកេ ឯកំ អាហារេ ទ្វេ ឥន្ទ្រិយេ ទ្វេ ឈានេ ទ្វេ មគ្គេ ឯកំ សម្បយុត្តេ ទ្វេ វិប្បយុត្តេ អត្ថិយា នត្ថិយា វិគតេ អវិគតេ ទ្វេ ។ ឯវំ គណេតព្វំ ។

បច្ចនីយានុលោមំ ។

បដិច្ចវារោ ។

សហជាតវារោ បដិច្ចវារសទិសោ ។

បច្ចយវារោ

(៦៧៦) អាចយគាមិំ ធម្មំ បច្ចយា អាចយគាមី ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា អាចយគាមី ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា ទ្វេ ខន្ធេ បច្ចយា ទ្វេ ខន្ធា ។

(៦៧៥) ក្នុងអារម្មណប្បច្ច័យ មានវារៈ២ ព្រោះហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ២ ក្នុងសហជាតប្បច្ច័យ មានវារៈ២ ក្នុងអញ្ញមញ្ញប្បច្ច័យ ក្នុងនិស្សយប្បច្ច័យ ក្នុងបុរេជាតប្បច្ច័យ ក្នុងអាសេវនប្បច្ច័យ ក្នុងកម្មប្បច្ច័យ មានវារៈ២ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ២ ក្នុងឈានប្បច្ច័យ មានវារៈ២ ក្នុងមគ្គប្បច្ច័យ មានវារៈ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ២ ក្នុងវិប្បយុត្តប្បច្ច័យ ក្នុងអត្ថិប្បច្ច័យ ក្នុងនត្ថិប្បច្ច័យ ក្នុងវិគតប្បច្ច័យ ក្នុងអវិគតប្បច្ច័យ មានវារៈ២ ។ បណ្ឌិត គប្បីរាប់យ៉ាងនេះ ។

ចប់ បច្ចនីយានុលោម ។

ចប់ បដិច្ចវារៈ ។

សហជាតវារៈ ប្រាកដស្មើដោយបដិច្ចវារៈដែរ ។

បច្ចយវារៈ

(៦៧៦) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនូវធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ៣ ពឹងផ្អែកនូវខន្ធ១ ដែលដល់នូវការសន្សំ ខន្ធ២ ពឹងផ្អែកនូវខន្ធ២ ។

អាចយគាមី ធម្មំ បច្ចយា នេវាចយគាមិនាបចយ-
គាមិ ធម្មោ ... ហេតុប្បច្ចយា អាចយគាមី ខន្ធេ
បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។ អាចយគាមី ធម្មំ
បច្ចយា អាចយគាមី ច នេវាចយគាមិនាបចយគាមី
ច ធម្មា ... អាចយគាមី ឯកំ ខន្ធំ បច្ចយា តយោ
ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... ។ អបច-
យគាមី ធម្មំ បច្ចយា ... តីណិ ។

(៤៧៧) នេវាចយគាមិនាបចយគាមី ធម្មំ បច្ច-
យា នេវាចយគាមិនាបចយគាមិ ធម្មោ ... ហេតុ-
ប្បច្ចយា នេវាចយគាមិនាបចយគាមី ឯកំ ខន្ធំ
បច្ចយា តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ
ខន្ធេ ... បដិសន្ធិក្ខណេ ខន្ធេ បច្ចយា វត្ថុ វត្ថុំ
បច្ចយា ខន្ធា ឯកំ មហាភូតំ បច្ចយា វត្ថុំ បច្ចយា
នេវាចយគាមិនាបចយគាមី ខន្ធា ។ នេវាចយគាមិ-
នាបចយគាមី ធម្មំ បច្ចយា អាចយគាមិ ធម្មោ ...
ហេតុប្បច្ចយា វត្ថុំ បច្ចយា អាចយគាមី ខន្ធា ។

ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹង
ធម៌ ដែលដល់នូវការសន្សំ ... ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋាន-
រូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ។ ធម៌ ដែល
ដល់នូវការសន្សំក្តី (ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិន
សន្សំក្តី) ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំ ... គឺ ខន្ធ ៣ ក្តី
ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវការសន្សំ នឹងខន្ធ
២ ... ។ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការមិនសន្សំ ... (បានដល់
ពាក្យបុច្ឆានិងវិសជ្ជនា) ៣ លើក ។

(៤៧៧) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិន
សន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការ
មិនសន្សំ ... ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី
ពឹងផ្អែកនឹងខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ
នឹងខន្ធ ២ ... វត្ថុ ពឹងផ្អែកនឹងខន្ធទាំងឡាយ ក្នុងខណៈនៃបដិ-
សន្ធិ ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ពឹងផ្អែកនឹងមហាភូត ១ ខន្ធ
ទាំងឡាយ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹង
ផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែល
មិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះហេតុប្ប-
ច្ច័យ គឺ ខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងវត្ថុ ។

នេវាចយគាមិនាបចយគាមឹ ធម្មំ បច្ចយា អបចយ-
គាមិ ធម្មោ ... វត្ថុំ បច្ចយា អបចយគាមី ខន្ធា ។
នេវាចយគាមិនាបចយគាមឹ ធម្មំ បច្ចយា អាចយគា-
មិ ច នេវាចយគាមិនាបចយគាមិ ច ធម្មា ... វត្ថុំ
បច្ចយា អាចយគាមី ខន្ធា មហាភូតេ បច្ចយា ចិត្ត-
សមុដ្ឋានំ រូបំ ។ នេវាចយគាមិនាបចយគាមឹ ធម្មំ
បច្ចយា អបចយគាមិ ច នេវាចយគាមិនាបចយគាមិ
ច ធម្មា ... វត្ថុំ បច្ចយា អបចយគាមី ខន្ធា មហា-
ភូតេ បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។

[៦៧៨] អាចយគាមិញ្ច នេវាចយគាមិនាបចយ-
គាមិញ្ច ធម្មំ បច្ចយា អាចយគាមិ ធម្មោ ... ហេតុ-
ប្បច្ចយា អាចយគាមឹ ឯកំ ខន្ធញ្ច វត្ថុញ្ច បច្ចយា
តយោ ខន្ធា ទ្វេ ខន្ធេ ... ។ អាចយគាមិញ្ច នេវាចយ-
គាមិនាបចយគាមិញ្ច ធម្មំ បច្ចយា នេវាចយគាមិនា-
បចយគាមិ ធម្មោ ... ហេតុប្បច្ចយា អាចយគាមី
ខន្ធេ ច មហាភូតេ ច បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។

ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការ
សន្សំ មិនដល់នូវការមិនសន្សំ ... គឺ ខន្ធទាំងឡាយ ដែល
ដល់នូវការមិនសន្សំ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំក្តី
ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំក្តី ពឹងផ្អែក
នឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ...
គឺ ខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុ-
ដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។ ធម៌ ដែលដល់នូវការ
មិនសន្សំក្តី ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំក្តី
ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ...
គឺ ខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងវត្ថុ ចិត្ត-
សមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។

(៦៧៨) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់
នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិន
សន្សំផង ... ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១
ដែលដល់នូវការសន្សំផង វត្ថុផង នឹងខន្ធ ២ ... ។ ធម៌ ដែលមិន
ដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់
នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិន
សន្សំផង ... ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹង
ខន្ធទាំងឡាយ ដែលដល់នូវការសន្សំផង មហាភូតទាំងឡាយផង ។

អាចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បច្ចយា អាចយគាមិ ច នេវាចយគាមិនាបចយគាមិ ច ធម្មា ឧប្បជ្ជន្តិ ហេតុបច្ចយា អាចយគាមី ឯកំ ខន្ធញ្ច វត្ថុញ្ច បច្ចយា តយោ ខន្ធា ទ្វេ ខន្ធេ ... អាចយគាមី ខន្ធេ ច មហាភូតេ ច បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។ អបចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បច្ចយា អបចយគាមី ធម្មា ... តីណិ ។

(៦៧៩) អាចយគាមិំ ធម្មំ បច្ចយា អាចយគាមី ធម្មា ឧប្បជ្ជន្តិ អារម្មណបច្ចយា អាចយគាមី ឯកំ ខន្ធំ បច្ចយា ។ អបចយគាមិំ ធម្មំ បច្ចយា ... ឯកំ ។

(៦៨០) នេវាចយគាមិនាបចយគាមិំ ធម្មំ បច្ចយា នេវាចយគាមិនាបចយគាមី ធម្មា ... នេវាចយគាមិនាបចយគាមិំ ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ វត្ថុំ បច្ចយា ខន្ធា ចក្ខាយតនំ បច្ចយា ចក្ខុវិញ្ញាណំ

ធម៌ ដែលដល់នូវការសន្សំក្តី ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំក្តី ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវការសន្សំផង វត្ថុផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការសន្សំផង មហាភូតទាំងឡាយផង ។ ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការមិនសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... (បាឋដល់វាក្យបុច្ឆា និងវិសជ្ជនា) ៣ លើក ។

(៦៧៩) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវការសន្សំ ។ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការមិនសន្សំ ... បាឋដល់ករៈ ១ ។

(៦៨០) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... គឺ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ នូវខន្ធ ២ ... ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ

កាយាយតនំ បច្ចយា កាយវិញ្ញាណំ វត្ថុំ បច្ចយា នេវាចយគាមិនាបចយគាមី ខន្ធា ។ នេវាចយគាមិនាបចយគាមី ធម្មំ បច្ចយា អាចយគាមី ធម្មោ ... វត្ថុំ បច្ចយា អាចយគាមី ខន្ធា ។ នេវាចយគាមិនាបចយគាមី ធម្មំ បច្ចយា អបចយគាមី ធម្មោ ... វត្ថុំ បច្ចយា អបចយគាមី ខន្ធា ។

(៤៨១) អាចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បច្ចយា អាចយគាមី ធម្មោ ... អាចយគាមី ឯកំ ខន្ធញ្ច វត្ថុញ្ច បច្ចយា តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(៤៨២) អបចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បច្ចយា អបចយគាមី ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អបចយគាមី ឯកំ ខន្ធញ្ច វត្ថុញ្ច បច្ចយា តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(៤៨៣) អាចយគាមី ធម្មំ បច្ចយា អាចយគាមី ធម្មោ ឧប្បជ្ជតិ អធិបតិប្បច្ចយា តីណិ ។

កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ខន្ធទាំងឡាយ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... គឺ ខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... គឺ ខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងវត្ថុ ។

(៤៨១) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែល មិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... គឺ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវការសន្សំផង វត្ថុផង (ពឹងផ្អែក) នឹងខន្ធ ២ ... ។

(៤៨២) ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការមិនសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវការមិនសន្សំផង វត្ថុផង (ពឹងផ្អែក) នឹងខន្ធ ២ ... ។

(៤៨៣) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ បានដល់វារៈ ៣

អបចយគាមិំ តីណិ ។ នេវាចយគាមិនាបចយគាមិ ... នេវាចយគាមី ឯកំ ... វត្ថុំ បច្ចយា នេវាចយគាមិនាបចយគាមី ខន្ធា ។ នេវាចយគាមិនាបចយគាមី ធម្មំ បច្ចយា អាចយគាមិ ធម្មោ ... ។ ឥធាបិ គណនា ហេតុសទិសា ។

(៦៨៤) អាចយគាមី ធម្មំ បច្ចយា អាចយគាមិ ធម្មោ ឧប្បជ្ជតិ អនន្តរប្បច្ចយា សមនន្តរប្បច្ចយា សហជាតប្បច្ចយា តីណិ ។ អបចយគាមិំ តីណិ ។ នេវាចយគាមិនាបចយគាមី ធម្មំ បច្ចយា នេវាចយគាមិនាបចយគាមិ ធម្មោ ... សហជាតប្បច្ចយា នេវាចយគាមិនាបចយគាមី ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ ។ សង្ខិត្តំ ។ អសញ្ញសត្តានំ ឯកំ មហាភូតំ ... ចក្ខាយតនំ បច្ចយា ចក្ខុវិញ្ញាណំ កាយាយតនំ បច្ចយា កាយវិញ្ញាណំ វត្ថុំ បច្ចយា ។ នេវាចយគាមិនាបចយគាមី ធម្មំ បច្ចយា អាចយគាមិ ធម្មោ ... សហជាតប្បច្ចយា ។ សង្ខិត្តំ ។ សព្វេ គណនា កាតព្វា ។

ធម៌ ដែលដល់នូវការមិនសន្សំ គឺ មានវារៈ ៣ លើក ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... (ពឹងផ្អែក) នឹងខន្ធ ១ ដែលមិនដល់នូវការសន្សំ ... ខន្ធទាំងឡាយ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ។ គំណ ក្នុងវារៈនេះ ប្រាកដស្មើដោយហេតុប្បច្ច័យដែរ ។

(៦៨៤) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ និង សហជាតប្បច្ច័យ បានដល់វារៈ ៣ លើក ។ ធម៌ ដែលដល់នូវការមិនសន្សំ មានវារៈ ៣ លើក ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះសហជាតប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។ សេចក្តីបំប្រួញ ។ (ពឹងផ្អែក) នឹងមហាភូត ១ របស់ពួកអសញ្ញសត្វ ... ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះសហជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ គំណ ទាំងអស់ បណ្ឌិតគប្បីធ្វើចុះ ។

(៤៨៥) អបចយគាមី ធម្មំ . . អញ្ញមញ្ញប្បច្ចយា និស្សយប្បច្ចយា ឧបនិស្សយប្បច្ចយា បុរេជាតប្បច្ចយា អាសេវនប្បច្ចយា កម្មប្បច្ចយា វិបាកប្បច្ចយា អាហារប្បច្ចយា ឥន្ទ្រិយប្បច្ចយា ឈានប្បច្ចយា មគ្គប្បច្ចយា សម្បយុត្តប្បច្ចយា វិប្បយុត្តប្បច្ចយា អត្ថិប្បច្ចយា នត្ថិប្បច្ចយា វិគតប្បច្ចយា អវិគតប្បច្ចយា ។

(៤៨៦) ហេតុយា សត្តរស អារម្មណេ សត្ត អធិបតិយា សត្តរស អនន្តរេ សត្ត សមនន្តរេ សត្ត សហជាតេ សត្តរស អញ្ញមញ្ញេ សត្ត និស្សយេ សត្តរស ឧបនិស្សយេ សត្ត បុរេជាតេ សត្ត អាសេវនេ សត្ត កម្មេ សត្តរស វិបាកេ ឯកំ អាហារេ សត្តរស ឥន្ទ្រិយេ ឈានេ មគ្គេ សត្តរស សម្បយុត្តេ សត្ត វិប្បយុត្តេ សត្តរស អត្ថិយា សត្តរស នត្ថិយា សត្ត វិគតេ សត្ត អវិគតេ សត្តរស ។ ឯវំ គណេតព្វំ ។

អនុលោមំ ។

(៤៨៥) **កំពីផ្លែកធម៌** ដែលដល់នូវការមិនសន្សំ . . . ព្រោះអញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

(៤៨៦) ក្នុងហេតុប្បច្ច័យ មានវារៈ ១៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុងកម្មប្បច្ច័យ មានវារៈ ១៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ១៧ ក្នុងឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ មានវារៈ ១៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១៧ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិត គប្បីរាប់យ៉ាងនេះ ។

ចប់ អនុលោម ។

(២៨៧) អាចយគាមឹ ធម្មំ បច្ចយា អាចយគាមី ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បច្ចយា វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។ នេវាចយគាមិនាបចយគាមឹ ធម្មំ បច្ចយា នេវាចយគាមិនាបចយគាមី ធម្មោ ... នហេតុប្បច្ចយា អហេតុកំ នេវាចយគាមិនាបចយគាមឹ ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... អហេតុកប្បដិសន្ធិក្ខណេ ។ សង្ខិត្តំ ។ អសញ្ញសត្តានំ ឯកំ មហាភូតំ ... ចក្ខាយតនំ បច្ចយា ចក្ខុវិញ្ញាណំ កាយាយតនំ បច្ចយា កាយវិញ្ញាណំ វត្ថុំ បច្ចយា អហេតុកា នេវាចយគាមិនាបចយគាមី ខន្ធា ។ នេវាចយគាមិនាបចយគាមឹ ធម្មំ បច្ចយា អាចយគាមី ធម្មោ ... នហេតុប្បច្ចយា វត្ថុំ បច្ចយា វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។

(២៨៧) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ជាអហេតុកៈ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ សេចក្តីបំប្រួញ ។ (ពឹងផ្អែក) នឹងមហាភូត ១ របស់ពួកអសញ្ញសត្វ ... ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ខន្ធទាំងឡាយ ជាអហេតុកៈ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។

(២៨៨) អាចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បច្ចយា អាចយគាមិ ធម្មោ ... ហេតុប្បច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ ច វត្ថុញ្ច បច្ចយា វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។

(២៨៩) អាចយគាមី ធម្មំ បច្ចយា នេវាចយគាមិនាបចយគាមិ ធម្មោ ... អារម្មណប្បច្ចយា ។ សង្ខិត្តំ ។ បដិច្ចវារសទិសំ ។

(២៩០) អាចយគាមី ធម្មំ បច្ចយា អាចយគាមិ ធម្មោ ឧប្បជ្ជតិ អធិបតិប្បច្ចយា តីណិ ។ អបចយគាមី ធម្មំ បច្ចយា អបចយគាមិ ធម្មោ ... អធិបតិប្បច្ចយា អបចយគាមី ខន្ធេ បច្ចយា អបចយគាមិ អធិបតិ ។ នេវាចយគាមិនាបចយគាមី ធម្មំ ។ សង្ខិត្តំ ។ អសញ្ញសត្តានំ ចក្ខាយតនំ បច្ចយា ចក្ខុវិញ្ញាណំ កាយាយតនំ ... វត្ថុំ បច្ចយា នេវាចយគាមិនាបចយគាមី ខន្ធា ។ នេវាចយគាមិនាបចយគាមី ធម្មំ បច្ចយា អាចយគាមិ ធម្មោ ...

(២៨៨) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះនូវហេតុប្បច្ច័យ គឺ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង វត្ថុផង ។

(២៨៩) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំ ... ព្រោះនូវអារម្មណប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ពាក្យនេះ ប្រាកដស្មើដោយបដិច្ចវារៈ ។

(២៩០) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះនូវអធិបតិប្បច្ច័យ បានដល់វារៈ ៣ លើក ។ ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការមិនសន្សំ ... ព្រោះនូវអធិបតិប្បច្ច័យ គឺ ធម៌ជាអធិបតិ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំ ។ (ពឹងផ្អែក) នឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ។ សេចក្តីបំប្រួញ ។ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ របស់ពួកអសញ្ញសត្វ (ពឹងផ្អែក) នឹងកាយាយតនៈ ... ខន្ធទាំងឡាយ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ...

អធិបតិបច្ចយា វត្ថុំ បច្ចយា អាចយគាមី ខន្ធា ។ នេវាចយគាមិនាបចយគាមឹ ធម្មំ បច្ចយា អបចយ-គាមិ ធម្មោ ... អធិបតិបច្ចយា វត្ថុំ បច្ចយា អ-បចយគាមិ អធិបតិ ។ នេវាចយគាមិនាបចយគាមឹ ធម្មំ បច្ចយា អាចយគាមិ ច នេវាចយគាមិនា-បចយគាមិ ច ធម្មា ... អធិបតិបច្ចយា វត្ថុំ បច្ចយា អាចយគាមី ខន្ធា មហាភូតេ បច្ចយា ចិត្ត-សមុដ្ឋានំ រូបំ ។

(៤៩១) អាចយគាមិញ្ច នេវាចយគាមិនាបចយ-គាមិញ្ច ធម្មំ បច្ចយា អាចយគាមិ ធម្មោ ... អ-ធិបតិបច្ចយា អាចយគាមឹ ឯកំ ខន្ធញ្ច វត្ថុញ្ច បច្ចយា តយោ ខន្ធា ទ្វេ ខន្ធេ ... ។ អាចយគា-មិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បច្ចយា នេវាចយគាមិនាបចយគាមិ ធម្មោ ... អាចយគាមី ខន្ធេ ច មហាភូតេ ច បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។

ព្រោះអធិបតិប្បច្ច័យ គឺ ខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះអធិ-បតិប្បច្ច័យ គឺ ធម៌ ជាអធិបតិ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំក្តី ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំក្តី ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះអធិបតិប្បច្ច័យ គឺ ខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។

(៤៩១) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះអធិបតិប្បច្ច័យ គឺ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវការសន្សំផង វត្ថុផង ពឹងផ្អែកនឹងខន្ធ ២ ... ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... គឺ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការសន្សំផង មហាភូតទាំងឡាយផង ។

អាចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បដិច្ច អាចយគាមិ ច នេវាចយគាមិនាបចយគាមិ ច ធម្មា ... អាចយគាមី ឯកំ ខន្ធញ្ច វត្ថុញ្ច បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... អាចយគាមី ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(៤៩២) អបចយគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បដិច្ច អបចយគាមិ ធម្មោ ... នអធិបតិប្បច្ចយា អបចយគាមី ខន្ធេ ច វត្ថុញ្ច បដិច្ច អបចយគាមិ អធិបតិ ។ នអនន្តរប្បច្ចយា នសមនន្តរប្បច្ចយា នអញ្ញមញ្ញប្បច្ចយា នឧបនិស្សយប្បច្ចយា នបុរេជាតប្បច្ចយា បដិច្ចវារសទិសា សត្ត បញ្ហា ។ នបច្ឆាជាតប្បច្ចយា បរិបុណ្ណំ ។

(៤៩៣) អាចយគាមី ធម្មំ បច្ចយា អាចយគាមិ ធម្មោ ... នអាសេវនប្បច្ចយា តីណិ ។ អបចយគាមី ធម្មំ បច្ចយា នេវាចយគាមិនាបចយគាមិ ធម្មោ ... នអាសេវនប្បច្ចយា អបចយគាមី ខន្ធេ បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។

ធម៌ ដែលដល់នូវការសន្សំក្តី ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំក្តី ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... គឺ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវការសន្សំផង វត្ថុផង (ពឹងផ្អែក) នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការសន្សំផង មហាភូតទាំងឡាយផង ។

(៤៩២) ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការមិនសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះនអធិបតិប្បច្ច័យ គឺ ធម៌ ជាអធិបតិ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំផង វត្ថុផង ។ ព្រោះនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ នឧបនិស្សយប្បច្ច័យ និងនបុរេជាតប្បច្ច័យ បញ្ហា ៧ ប្រាកដស្មើដោយបដិច្ចវារៈ ។ ព្រោះនបច្ឆាជាតប្បច្ច័យ (នេះ) ជាពាក្យគ្រប់គ្រាន់ ។

(៤៩៣) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំ ... ព្រោះនអាសេវនប្បច្ច័យ បាននូវវារៈ ៣ លើក ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការមិនសន្សំ ... ព្រោះនអាសេវនប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំ ។

នេវាចយគាមិនាបចយគាមី ធម្មំ បច្ចយា នេវាចយ-
គាមិនាបចយគាមី ធម្មោ ។ សង្ខិត្តំ ។ អសញ្ញ-
សត្តានំ ... ចក្ខាយតនំ បច្ចយា កាយាយតនំ
បច្ចយា វត្ថុំ បច្ចយា នេវាចយគាមិនាបចយគាមី
ខន្ធា ។ នេវាចយគាមិនាបចយគាមី ធម្មំ បច្ចយា
អាចយគាមី ធម្មោ ... ឧអាសេវនប្បច្ចយា វត្ថុំ
បច្ចយា អាចយគាមី ខន្ធា ។ នេវាចយគាមិនាប-
ចយគាមី ធម្មំ បច្ចយា អាចយគាមី ច នេវាចយ-
គាមិនាបចយគាមី ច ធម្មា ... វត្ថុំ បច្ចយា អាច-
យគាមី ខន្ធា មហាភូតេ បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។

(២៩៦) អាចយគាមិញ្ច នេវាចយគាមិ-
នាបចយគាមិញ្ច ធម្មំ បច្ចយា អាចយគាមី
ធម្មោ ... អាចយគាមី ឯកំ ខន្ធញ្ច វត្ថុញ្ច
បច្ចយា តយោ ខន្ធា ទ្វេ ខន្ធេ ... ។ អាច-
យគាមិញ្ច នេវាចយគាមិនាបចយគាមិញ្ច ធម្មំ
បច្ចយា នេវាចយគាមិនាបចយគាមី ធម្មោ ...

ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនូវធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ។ សេចក្តីបំប្រួញ ។ របស់ពួកអសញ្ញសត្វ ... ខន្ធទាំងឡាយ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនូវចក្ខាយតនៈ ពឹងផ្អែកនូវកាយាយតនៈ ពឹងផ្អែកនូវវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនូវធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះឧកាសេវនប្បច្ច័យ គឺ ខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ពឹងផ្អែកនូវវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំក្តី ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំក្តី ពឹងផ្អែកនូវធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... គឺ ខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ពឹងផ្អែកនូវវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនូវមហាភូតទាំងឡាយ ។

(២៩៦) ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនូវធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... គឺ ខន្ធ ៣ ពឹងផ្អែកនូវខន្ធ ១ ដែលដល់នូវការសន្សំផង វត្ថុផង (ពឹងផ្អែក) នូវខន្ធ ២ ... ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនូវធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ...

អាចយគាមី ខន្ធេ ច មហាភូតេ ច បច្ចយា ចិត្ត-
សមុដ្ឋានំ រូបំ ។ អាចយគាមិញ្ច នេវាចយគាមិនា-
បចយគាមិញ្ច ធម្មំ បច្ចយា អាចយគាមី ច នេវា-
ចយគាមិនាបចយគាមី ច ធម្មា ... អាចយគាមី
ឯកំ ខន្ធញ្ច វត្ថុញ្ច បច្ចយា តយោ ខន្ធា ទ្វេ ខន្ធេ
ច វត្ថុញ្ច បច្ចយា អាចយគាមី ខន្ធេ ច មហាភូតេ
ច បច្ចយា ចិត្តសមុដ្ឋានំ រូបំ ។ អាចយគាមិញ្ច
នេវាចយគាមិនាបចយគាមិញ្ច ធម្មំ បច្ចយា នេវាច-
យគាមិនាបចយគាមី ធម្មោ ... នអាសេវនប្បច្ចយា
អបចយគាមី ខន្ធេ ច មហាភូតេ ច បច្ចយា ចិត្ត-
សមុដ្ឋានំ រូបំ ។

(២៩៥) អាចយគាមិំ ធម្មំ បច្ចយា អាចយគាមី
ធម្មោ ឧប្បជ្ជតិ នកម្មប្បច្ចយា អាចយគាមី ខន្ធេ
បច្ចយា អាចយគាមី ចេតនា ។ អបចយគាមិំ ធម្មំ
បច្ចយា អបចយគាមី ធម្មោ ... នកម្មប្បច្ចយា
អបចយគាមី ខន្ធេ បច្ចយា អបចយគាមី ចេតនា ។

គឺ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការសន្សំ
ផង នឹងមហាភូតទាំងឡាយផង ។ ធម៌ ដែលដល់នូវការសន្សំក្តី
ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំក្តី ពឹងផ្អែក
នឹងធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ
មិនដល់នូវការមិនសន្សំផង ... គឺ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១
ដែលដល់នូវការសន្សំផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធ ២
ផង វត្ថុផង ខន្ធទាំងឡាយ ដែលដល់នូវការសន្សំផង មហាភូត
ទាំងឡាយផង ។ ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការ
មិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិន
ដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះនអាសេវ-
នប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់
នូវការមិនសន្សំផង មហាភូតទាំងឡាយផង ។

(២៩៥) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែល
ដល់នូវការសន្សំ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ដែល
ដល់នូវការសន្សំ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការសន្សំ ។
ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការ
មិនសន្សំ ... ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ដែលដល់នូវការ
មិនសន្សំ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំ ។

នេវាចយគាមិនាបចយគាមិំ ធម្មំ បច្ចយា នេវាចយ-គាមិនាបចយគាមី ធម្មោ ... នកម្មប្បច្ចយា នេវា-ចយគាមិនាបចយគាមី ខន្ធេ បច្ចយា នេវាចយគា-មិនាបចយគាមិនី ចេតនា ពាហិរំ ... អាហារសមុដ្ឋា-នំ ... ឧតុសមុដ្ឋានំ ... វត្ថុំ បច្ចយា នេវាចយគាមិ-នាបចយគាមិនី ចេតនា ។ នេវាចយគាមិនាបចយគាមិំ ធម្មំ បច្ចយា អាចយគាមី ធម្មោ ... នកម្មប្បច្ចយា វត្ថុំ បច្ចយា អាចយគាមិនី ចេតនា ។ នេវាចយគាមិ-នាបចយគាមិំ ធម្មំ បច្ចយា អបចយគាមី ធម្មោ ... នកម្មប្បច្ចយា វត្ថុំ បច្ចយា អបចយគាមិនី ចេតនា ។

(៤៩៦) អាចយគាមិញ្ច នេវាចយគាមិនាបចយ-គាមិញ្ច ធម្មំ បច្ចយា អាចយគាមី ធម្មោ ... ន-កម្មប្បច្ចយា អាចយគាមី ខន្ធេ ច វត្ថុញ្ច បច្ចយា អាចយគាមិនី ចេតនា ។

ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុ-សមុដ្ឋាន ... ចេតនា ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងវត្ថុ ។

(៤៩៦) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការសន្សំផង វត្ថុផង ។

(២៩៧) អបចយគាមិញ្ច នេវាចយគាមិនាបចយ-គាមិញ្ច ធម្មំ បច្ចយា អបចយគាមិ ធម្មោ ... កម្មប្បច្ចយា អបចយគាមី ខន្ធេ ច វត្ថុញ្ច បច្ច-យា អាចយគាមិ ចេតនា ។

(២៩៨) អាចយគាមី ធម្មំ បច្ចយា អាចយគាមិ ធម្មោ ... វិបាកប្បច្ចយា ។ បរិបុណ្ណំ កាតព្វំ ។ បដិសន្ធិក្ខណេ នត្ថិ ។

(២៩៩) នេវាចយគាមិនាបចយគាមី ធម្មំ បច្ចយា នេវាចយគាមិនាបចយគាមិ ធម្មោ ... អាហារ-ប្បច្ចយា ពាហិរំ ... ឧតុសមុដ្ឋានំ ... អសញ្ញ-សត្តានំ ... ។

(៣០០) ... ឥន្ទ្រិយប្បច្ចយា ពាហិរំ ... អាហារសមុដ្ឋានំ ... ឧតុសមុដ្ឋានំ ... អសញ្ញសត្តានំ មហាភូតេ បច្ចយា រូបជីវិតិន្ទ្រិយំ ។

(៣០១) ... ឈានប្បច្ចយា បញ្ចវិញ្ញាណំ ពាហិរំ ... អាហារសមុដ្ឋានំ ... ឧតុសមុដ្ឋានំ ... អ-សញ្ញសត្តានំ ... ចក្ខាយតនំ បច្ចយា ចក្ខុវិញ្ញាណំ កាយាយតនំ ... ។

(២៩៧) ធម៌ ដែលដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការមិនសន្សំផង ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ... ព្រោះកម្មប្បច្ច័យ គឺ ចេតនា ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំផង វត្ថុផង ។

(២៩៨) ធម៌ ដែលដល់នូវការសន្សំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវការសន្សំ ... ព្រោះវិបាកប្បច្ច័យ ។ បណ្ឌិតគប្បីធ្វើឲ្យបរិបូណ៌ (គ្រប់បទទាំងអស់) ។ (អាចយគាមិធម៌) មិនមាន ក្នុងខណៈនៃបដិសន្ធិទេ ។

(២៩៩) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ពឹងផ្អែកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះអាហារប្បច្ច័យ គឺ ពាហិរ ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញសត្វ ... ។

(៣០០) ... ព្រោះឥន្ទ្រិយប្បច្ច័យ គឺ ពាហិរ ... អាហារ-សមុដ្ឋាន ... ឧតុសមុដ្ឋាន ... រូបជីវិតិន្ទ្រិយ ពឹងផ្អែកនឹងមហា-ភូតទាំងឡាយ របស់ពួកអសញ្ញសត្វ ។

(៣០១) ... ព្រោះឈានប្បច្ច័យ គឺ បញ្ចវិញ្ញាណ (ពឹងផ្អែក) នឹងពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញសត្វ... ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ (កាយវិញ្ញាណ ពឹងផ្អែក) នឹងកាយាយតនៈ ... ។

(៣០៦) ... នមគ្គប្បច្ចយា អហេតុកា នេវាច-
យគាមិនាបចយគាមី ។ សង្ខិត្តំ ។ អសញ្ញសត្តានំ
ឯកំ មហាភូតំ ... ចក្ខាយតនំ បច្ចយា ចក្ខុ-
វិញ្ញាណំ កាយាយតនំ បច្ចយា វត្ថុំ បច្ចយា អ-
ហេតុកា នេវាចយគាមី ... នសម្បយុត្តប្បច្ចយា
នវិប្បយុត្តប្បច្ចយា ។ បដិច្ចវារសទិសំ តីណិ ។
នោនត្ថិប្បច្ចយា នោវិគតប្បច្ចយា ។

(៣០៧) នហេតុយា ចត្តារិ នអារម្មណេ បញ្ច
នអធិបតិយា ទ្វាទស នអនន្តរេ បញ្ច នសមនន្តរេ
នអញ្ញមញ្ញេ នឧបនិស្សយេ បញ្ច នបុរេជាតេ សត្ត
នបច្ឆាជាតេ សត្តរស នអាសេវនេ ឯកាទស
នកម្មេ សត្ត នវិបាកេ សត្តរស នអាហារេ ន-
ឥន្ទ្រិយេ នឈានេ នមគ្គេ ឯកំ នសម្បយុត្តេ បញ្ច
នវិប្បយុត្តេ តីណិ នោនត្ថិយា នោវិគតេ បញ្ច ។
ឯវំ គណេតព្វំ ។

បច្ចនីយំ ។

(៣០៦) ... ព្រោះនមគ្គប្បច្ច័យ គឺ ធម៌ ដែលមិនដល់នូវការ
សន្សំ មិនដល់នូវការមិនសន្សំ ជាអហេតុកៈ ។ សេចក្តីបង្រួម ។
មហាភូត ១ របស់ពួកអសញ្ញសត្វ ... ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខា-
យតនៈ (កាយវិញ្ញាណ) ពឹងផ្អែកនឹងកាយាយតនៈ ធម៌ ដែលមិនដល់
នូវការសន្សំ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ ... ព្រោះនសម្បយុត្តប្ប-
ច្ច័យ និងនវិប្បយុត្តប្បច្ច័យ ។ (ការៈនៃបុច្ឆា និងវិសជ្ជនា) ៣ លើក
ប្រាកដស្មើដោយបដិច្ចវារៈដែរ ។ ព្រោះនោនត្ថិប្បច្ច័យ និងនោវិគត-
ប្បច្ច័យ ។

(៣០៧) ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ
មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១២ ក្នុងនអនន្តរប្បច្ច័យ
មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្ស-
យប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆា-
ជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១១ ក្នុងន-
កម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១៧ ក្នុងនអាហា-
រប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ និងនមគ្គប្បច្ច័យ មានវារៈ ១
ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣
ក្នុងនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិត គប្បី
រាប់យ៉ាងនេះ ។

ចប់ បច្ចនីយៈ ។

(៣០៤) ហេតុប្បច្ចយា នអារម្មណេ បញ្ច ... នអធិបតិយា ទ្វាទស នអនន្តរេ នសមនន្តរេ នអញ្ញមញ្ញេ នឧបនិស្សយេ បញ្ច នបុរេជាតេ សត្ត នបច្ឆាជាតេ សត្តរស នអាសេវនេ ឯកាទស នកម្មេ សត្ត នវិបាកេ សត្តរស នសម្បយុត្តេ បញ្ច នវិប្បយុត្តេ តីណិ នោនត្ថិយា នោវិគតេ បញ្ច ។ ឯវំ គណេតព្វំ ។

អនុលោមប្បច្ចនីយំ ។

(៣០៥) នហេតុប្បច្ចយា អារម្មណេ ចត្តារិ ... អនន្តរេ សមនន្តរេ សហជាតេ អញ្ញមញ្ញេ និស្សយេ ឧបនិស្សយេ បុរេជាតេ អាសេវនេ កម្មេ ចត្តារិ វិបាកេ ឯកំ អាហារេ ចត្តារិ ឥន្ទ្រិយេ ឈានេ ចត្តារិ មគ្គេ តីណិ សម្បយុត្តេ វិប្បយុត្តេ អត្ថិយា នត្ថិយា វិគតេ ចត្តារិ អវិគតេ ចត្តារិ ។ ឯវំ គណេតព្វំ ។

បច្ចនីយានុលោមំ ។

បច្ចយវារោ សមត្តោ ។

និស្សយវារោ បច្ចយវារសទិសោ ។

(៣០៤) ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១២ ក្នុងនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១១ ក្នុងនកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិត គប្បីរាប់យ៉ាងនេះ ។

ចប់ អនុលោមប្បច្ចនីយៈ ។

(៣០៥) ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ និងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ និងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។ បណ្ឌិត គប្បីរាប់យ៉ាងនេះចុះ ។

ចប់ បច្ចនីយានុលោម ។

ចប់ បច្ចយវារៈ ។

និស្សយវារៈ ប្រាកដស្មើដោយបច្ចយវារៈដែរ ។

សំសដ្ឋវារោ

(៣០២) អាចយគាមឹ ធម្មំ សំសដ្ឋោ អាចយគាមី ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អាចយគាមឹ ឯកំ ខន្ធំ សំសដ្ឋា តយោ ខន្ធា ទ្វេ ខន្ធេ សំសដ្ឋា ។

(៣០៣) អបចយគាមឹ ធម្មំ សំសដ្ឋោ អបចយគាមី ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អបចយគាមឹ ឯកំ ខន្ធំ សំសដ្ឋា តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(៣០៤) នេវាចយគាមិនាបចយគាមឹ ធម្មំ សំសដ្ឋោ នេវាចយគាមិនាបចយគាមី ធម្មោ ... នេវាចយគាមិនាបចយគាមឹ ឯកំ ខន្ធំ សំសដ្ឋា តយោ ខន្ធា ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ ... ។

(៣០៥) អាចយគាមឹ ធម្មំ សំសដ្ឋោ អាចយគាមី ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អធិបតិប្បច្ចយា អនន្តរប្បច្ចយា សមនន្តរប្បច្ចយា សហជាតប្បច្ចយា អញ្ញមញ្ញប្បច្ចយា និស្សយប្បច្ចយា ឧបនិស្សយប្បច្ចយា បុរេជាតប្បច្ចយា អាសេវនប្បច្ចយា កម្មប្បច្ចយា វិបាកប្បច្ចយា អាហារប្បច្ចយា ឥន្ទ្រិយប្បច្ចយា ឈានប្បច្ចយា មគ្គប្បច្ចយា សម្បយុត្តប្បច្ចយា វិប្បយុត្តប្បច្ចយា អត្ថិប្បច្ចយា នត្ថិប្បច្ចយា វិគតប្បច្ចយា អវិគតប្បច្ចយា ។

សំសដ្ឋវារៈ

(៣០២) ធម៌ ដែលដល់នូវការសន្សំ ច្រឡំនឹងធម៌ ដែលដល់នូវការសន្សំ កើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ច្រឡំនឹងខន្ធ ១ ដែលដល់នូវការសន្សំ ច្រឡំនឹងខន្ធ ២ ។

(៣០៣) ធម៌ ដែលដល់នូវការមិនសន្សំ ច្រឡំនឹងធម៌ ដែលដល់នូវការមិនសន្សំ កើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ច្រឡំនឹងខន្ធ ១ ដែលដល់នូវការមិនសន្សំ នឹងខន្ធ ២ ... ។

(៣០៤) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ច្រឡំនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... គឺ ខន្ធ ៣ ច្រឡំនឹងខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

(៣០៥) ធម៌ ដែលដល់នូវការសន្សំ ច្រឡំនឹងធម៌ ដែលដល់នូវការសន្សំ កើតឡើង ព្រោះអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

(៣១០) ហេតុយា តីណិ អារម្មណេ អធិប-តិយា អនន្តរេ សមនន្តរេ សហជាតេ អញ្ញមញ្ញេ និស្សយេ ឧបនិស្សយេ បុរេជាតេ អាសេវនេ កម្មេ សព្វត្ថ តីណិ ។ វិបាកេ ឯកំ អាហារេ តីណិ ឥន្ទ្រិយេ ឈានេ មគ្គេ សម្បយុត្តេ វិប្បយុត្តេ អត្ថិយា នត្ថិយា វិគតេ អវិគតេ តីណិ ។ ឯវំ គណេតព្វំ ។

អនុលោមំ ។

(៣១១) អាចយគាមឹ ធម្មំ សំសដ្ឋោ អាចយ-គាមិ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា វិចិកិច្ឆា-សហគតេ ឧទ្ធច្ចសហគតេ ខន្ធេ សំសដ្ឋោ វិចិ-កិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។

(៣១២) នេវាចយគាមិនាបចយគាមឹ ធម្មំ សំ-សដ្ឋោ នេវាចយគាមិនាបចយគាមិ ធម្មោ ... ន-ហេតុប្បច្ចយា អហេតុកំ នេវាចយគាមិនាបចយគាមឹ ឯកំ ខន្ធំ សំសដ្ឋា តយោ ខន្ធា ទ្វេ ខន្ធេ ... អហេតុកប្បដិសន្ធិក្ខណេ ... ។

(៣១០) ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ និងកម្មប្បច្ច័យ មានវារៈ ៣ ទាំងអស់ ។ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្ប-យុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះ ។

ចប់ អនុលោម ។

(៣១១) ធម៌ ដែលដល់នូវការសន្សំ ប្រឡូកនឹងធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ប្រឡូកនឹងខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

(៣១២) ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ប្រឡូកនឹងធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ... ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ ប្រឡូកនឹងខន្ធ ១ ជាអហេតុកៈ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ នឹងខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។

អាចយគាមិត្តិកេ សំសដ្ឋវារោ

(៣១៣) អាចយគាមី ធម្មំ សំសដ្ឋោ អាចយគាមី ធម្មោ ... នអធិបតិប្បច្ចយា នបុរេជាតប្បច្ចយា នបច្ឆាជាតប្បច្ចយា នអាសេវនប្បច្ចយា អាចយគាមី ឯកំ ខន្ធំ សំសដ្ឋា តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(៣១៤) នេវាចយគាមិនាបចយគាមី ធម្មំ សំសដ្ឋោ នេវាចយគាមិនាបចយគាមី ធម្មោ ... នអាសេវនប្បច្ចយា នេវាចយគាមិនាបចយគាមី ឯកំ ខន្ធំ សំសដ្ឋា បដិសន្ធិក្ខណេ ... នកម្មប្បច្ចយា នវិបាកប្បច្ចយា នឈានប្បច្ចយា នមគ្គប្បច្ចយា នវិប្បយុត្តប្បច្ចយា ។

(៣១៥) នហេតុយា ទ្វេ នអធិបតិយា តីណិ នបុរេជាតេ តីណិ នបច្ឆាជាតេ តីណិ នអាសេវនេ ទ្វេ នកម្មេ តីណិ នវិបាកេ តីណិ នឈានេ ឯកំ នមគ្គេ ឯកំ នវិប្បយុត្តេ តីណិ ។ ឯវំ គណេតព្វំ ។

បច្ចនីយំ ។

អាចយគាមិត្តិកៈ សំសដ្ឋវារៈ

(៣១៣) ធម៌ ដែលដល់នូវការសន្សំ ច្រឡំនឹងធម៌ ដែលដល់នូវការសន្សំ ... ព្រោះនអធិបតិប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ និងនអាសេវនប្បច្ច័យ គឺ ខន្ធ ៣ ច្រឡំនឹងខន្ធ ១ ដែលដល់នូវការសន្សំ នឹងខន្ធ ២ ... ។

